# តារាងបែងចែកចំណូលចរន្ត និងចំណូលមូលធន ថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១

ឯកតា: លានរៀល

| ជំពូក | បរិយាយ | ចំនួនទឹកប្រាក់ |
|---|---|---|
| | ផ្នែក ២-អគ្គនាយកដ្ឋានពន្ធដារ | **2.415.810,0** |
| 70 | ចំណូលសារពើពន្ធក្នុងប្រទេស | 2.414.000,0 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 1.810,0 |
| | ផ្នែក ៣- ទីស្តីការក្រសួង | **3.406.395,0** |
| | -ចំណូលចរន្ត | **406.945,0** |
| 70 | ចំណូលសារពើពន្ធក្នុងប្រទេស | 73.221,0 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 25.724,0 |
| 76 | ផលហិរញ្ញវត្ថុ | 53.000,0 |
| 77 | ផលផ្សេងៗ និងផលពិសេស | 255.000,0 |
| | -ចំណូលមូលធន | **2.999.450,0** |
| 27 | អចលកម្មហិរញ្ញវត្ថុ | 57.000,0 |
| 13 | ឧបត្ថម្ភកធន | 1.755.450,0 |
| 16 | ការខ្ចី និងបំណុលប្រហាក់ប្រហែល | 1.187.000,0 |
| | ផ្នែក ៩- មន្ទីរជំនាញរាជធានី-ខេត្ត | **187,0** |
| 72 | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 111,0 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 76,0 |
| | **១១. ក្រសួងព័ត៌មាន** | **1.360,3** |
| | ផ្នែក ១- ក្រសួង | **1.211,8** |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 1.211,8 |
| | ផ្នែក ៩- មន្ទីរជំនាញរាជធានី-ខេត្ត | **148,5** |
| 72 | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 43,8 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 104,7 |
| | **១២. ក្រសួងសុខាភិបាល** | **2.058,0** |
| | ផ្នែក ១- ក្រសួង | **1.783,0** |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 1.783,0 |
| | ផ្នែក ៩- មន្ទីរជំនាញរាជធានី-ខេត្ត | **275,0** |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 275,0 |
| | **១៣. ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល** | **18.818,4** |
| | ផ្នែក ១- ក្រសួង | **16.595,5** |
| 70 | ចំណូលសារពើពន្ធក្នុងប្រទេស | 599,2 |
| 72 | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 7.684,3 |

# តារាងបែងចែកចំណូលចរន្ត និងចំណូលមូលធន ថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១

ឯកតា:លានរៀល

| ជំពូក | បរិយាយ | ចំនួនទឹកប្រាក់ |
|---|---|---|
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 5.439,0 |
| 74 | ផលពីការផាកពិន័យ និងការដាក់ទណ្ឌកម្ម | 85,0 |
| 76 | ផលហិរញ្ញវត្ថុផ្សេងៗទៀត | 123,0 |
| 77 | ផលផ្សេងៗ និងផលពិសេស | 2.665,0 |
| | ផ្នែក ៩- មន្ទីរជំនាញរាជធានី-ខេត្ត | **2.222,9** |
| 72 | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 2.130,5 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 92,4 |
| | **១៥. ក្រសួងពាណិជ្ជកម្ម** | **120.997,9** |
| | ផ្នែក ១- ក្រសួង | **120.791,8** |
| 71 | ចំណូលលើពាណិជ្ជកម្មក្រៅប្រទេស | 90.000,0 |
| 72 | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 527,0 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 30.264,8 |
| | ផ្នែក ៩- មន្ទីរជំនាញរាជធានី-ខេត្ត | **206,1** |
| 70 | ចំណូលសារពើពន្ធក្នុងប្រទេស | 1,5 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 204,6 |
| | **១៦. ក្រសួងអប់រំ យុវជន និងកីឡា** | **776,6** |
| | ផ្នែក ១- អប់រំ | **438,0** |
| 72 | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 373,0 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 65,0 |
| | ផ្នែក ៩- មន្ទីរជំនាញរាជធានី-ខេត្ត | **338,6** |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 338,6 |
| | **១៧. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | **101.757,0** |
| | ផ្នែក ១- ក្រសួង | **101.379,0** |
| 72 | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 31.261,0 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 3.718,0 |
| 74 | ផលពីការផាកពិន័យ និងការដាក់ទណ្ឌកម្ម | 800,0 |
| 77 | ផលផ្សេងៗ និងផលពិសេស | 65.600,0 |
| | ផ្នែក ៩- មន្ទីរជំនាញរាជធានី-ខេត្ត | **378,0** |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 334,0 |
| 74 | ផលពីការផាកពិន័យ និងការដាក់ទណ្ឌកម្ម | 44,0 |

# តារាងបែងចែកចំណូលចរន្ត និងចំណូលមូលធន
# ថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១

ឯកតា: លានរៀល

| ជំពូក | បរិយាយ | ចំនួនទឹកប្រាក់ |
|---|---|---|
| | **១៨. ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ** | **1.753,5** |
| | ផ្នែក ១- ក្រសួង | **1.713,5** |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 1.713,5 |
| | ផ្នែក ៩- មន្ទីរជំនាញរាជធានី-ខេត្ត | **40,0** |
| 72 | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 32,0 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 8,0 |
| | **១៩. ក្រសួងបរិស្ថាន** | **549,0** |
| | ផ្នែក ១- ក្រសួង | **510,0** |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 490,0 |
| 74 | ផលពីការផាកពិន័យ និងការដាក់ទណ្ឌកម្ម | 20,0 |
| | ផ្នែក ៩- មន្ទីរជំនាញរាជធានី-ខេត្ត | **39,0** |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 39,0 |
| | **២២. ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍** | **77.473,8** |
| | ផ្នែក ១- ក្រសួង | **75.956,0** |
| 70 | ចំណូលសារពើពន្ធក្នុងប្រទេស | 5.310,0 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 70.646,0 |
| | ផ្នែក ៩- មន្ទីរជំនាញរាជធានី-ខេត្ត | **1.517,8** |
| 70 | ចំណូលសារពើពន្ធក្នុងប្រទេស | 11,7 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 1.506,1 |
| | **២៥. ក្រសួងសាធារណការ និងដឹកជញ្ជូន** | **13.384,2** |
| | ផ្នែក ១- ក្រសួង | **11.886,9** |
| 72 | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 8.235,0 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 3.621,9 |
| 74 | ផលពីការផាកពិន័យ និងការដាក់ទណ្ឌកម្ម | 30,0 |
| | ផ្នែក ៩- មន្ទីរជំនាញរាជធានី-ខេត្ត | **1.497,3** |
| 72 | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 5,0 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 1.477,3 |
| 74 | ផលពីការផាកពិន័យ និងការដាក់ទណ្ឌកម្ម | 15,0 |
| | **២៦. ក្រសួងយុត្តិធម៌** | **1.511,0** |
| | **ផ្នែក ២- តុលាការកំពូល** | **150,0** |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 150,0 |

# តារាងបែងចែកចំណូលចរន្ត និងចំណូលមូលធន ថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១

ឯកតា: លានរៀល

| ជំពូក | បរិយាយ | ចំនួនទឹកប្រាក់ |
|---|---|---|
| | **ផ្នែក ៤- សាលាឧទ្ធរណ៍** | 291,0 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 266,0 |
| 74 | ផលពីការផាកពិន័យ និងការដាក់ទណ្ឌកម្ម | 25,0 |
| | **ផ្នែក ៩- មន្ទីរជំនាញរាជធានី-ខេត្ត** | 1.070,0 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 670,0 |
| 74 | ផលពីការផាកពិន័យ និងការដាក់ទណ្ឌកម្ម | 400,0 |
| | **២៧. ក្រសួងទេសចរណ៍** | **7.181,6** |
| | ផ្នែក ១- ក្រសួង | **7.078,9** |
| 70 | ចំណូលសារពើពន្ធក្នុងប្រទេស | 1.622,0 |
| 72 | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 1.818,4 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 3.638,5 |
| | ផ្នែក ៩- មន្ទីរជំនាញរាជធានី-ខេត្ត | **102,7** |
| 70 | ចំណូលសារពើពន្ធក្នុងប្រទេស | 57,5 |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 45,2 |
| | **២៨. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** | **3.930,6** |
| | ផ្នែក ១- ក្រសួង | **475,6** |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 475,6 |
| | ផ្នែក ៩- មន្ទីរជំនាញរាជធានី-ខេត្ត | **3.455,0** |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 3.455,0 |
| | **៣២. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** | **2.210,1** |
| | ផ្នែក ១- ក្រសួង | **1.221,9** |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 1.221,9 |
| | ផ្នែក ៩- មន្ទីរជំនាញរាជធានី-ខេត្ត | **988,2** |
| 73 | ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 988,2 |
| | **ធនាគារជាតិនៃកម្ពុជា** | **50.000,0** |
| 72 | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 50.000,0 |
| | **សរុបចំណូលចរន្ត** | 6.499.652,0 |
| | **ក្រសួង** | 6.481.073,9 |
| | **មន្ទីរជំនាញរាជធានី-ខេត្ត** | 18.578,1 |
| | **សរុបចំណូលមូលធន** | 2.999.450,0 |
| | **សរុបចំណូលថវិកាថ្នាក់ជាតិ** | 9.499.102,0 |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ...១៥៤...អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការផ្ទេរឥណទានថវិកា

---

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ,ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ , ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៨/០២០ , ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០១០
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក , ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក , ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែមនិង កែសំរួលនាយកដ្ឋាន មួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៣៨ អនក្រ.បក, ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០១០
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ២៥០ លានរៀល (ពីររយហាសិបលានរៀលគត់) ពីជំពូក ០៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក ៦៥ (ឧបត្ថម្ភកធន និង ជំនួយសង្គម) ជូនទីស្តីការគណៈរដ្ឋមន្ត្រីសំរាប់ការគ្រប់គ្រងឆ្នាំ ២០១០ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះតាម គណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្រាប់ផ្តល់ជូនអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន សំរាប់បន្តដំណើរការចំណាយរហូតដល់ដំណាច់ឆ្នាំ ២០១០ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

**បានយកសេចក្តីជំរាបជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ...១៩៨...អនក្រ.បក

**អនុក្រឹត្យ**

**ស្ដីពីការផ្ទេរឥណទានថវិកា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៨/០២០ ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពី ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០១០
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្ដីពីការនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០០៨ ស្ដីពីការបំពេញបន្ថែមនិង កែសំរួលនាយកដ្ឋាន មួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៣៨ អនក្រ.បក. ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩ ស្ដីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០១០
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ២៥០ លានរៀល (ពីររយហាសិបលានរៀលគត់) ពីជំពូក ០៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក ៦៥ (ឧបត្ថម្ភកធន និង ជំនួយសង្គម) ជូនទីស្តីការគណៈរដ្ឋមន្ត្រីសំរាប់ការគ្រប់គ្រងឆ្នាំ ២០១០ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះតាម គណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីផ្តល់ជូនគណៈកម្មាធិការជាតិសំរបសំរួលកិច្ចការបញ្ជូនកងកំលាំងចូលរួមថែរក្សាសន្តិភាពរបស់អ.ស.ប សំរាប់រៀបចំពិធីជូនដំណើរ និងផ្តល់ប្រាក់ហោប៉ៅដល់នាយទាហាននៃកងវិស្វកម្ម លេខ ៥១៣ ចេញទៅបំពេញបេសកកម្ម អ.ស.ប នៅប្រទេស លីបង់ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

**បានយកសេចក្តីជំរាបជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៧៦៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកំណត់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន តាមលក្ខន្តិកៈដោយឡែក

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០១ / ២៤១ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

## សម្រេច

**មាត្រា ១ :** ត្រូវបានកំណត់ជាក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន និងចាត់បញ្ចូលទៅក្នុងឋានន្តរស័ក្តិគ្រូបង្រៀនកម្រិតមូលដ្ឋាន តាមលក្ខន្តិកៈដោយឡែកនូវមន្ត្រីរាជការស៊ីវិល របស់ក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ÷

| ល.រ | គោត្តនាម និង នាម | ភេទ | ថ្ងៃខែឆ្នាំកំណើត | ឋានន្តរស័ក្តិ និងថ្នាក់ | កាលបរិច្ឆេទ |
|---|---|---|---|---|---|
| **មន្ទីរអប់រំ យុវជន និងកីឡាខេត្តតាកែវ** | | | | | |
| ១ | នេង សាវ៉ន | ប | ១៦-១១-៨៤ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ | ០១-១០-០៩ |
| ២ | ជួន ដានី | ស | ០៩-០៧-៨២ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ | ០១-១០-០៩ |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១២៦ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៩២ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៥៦ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីក្រមការ
- បានឃើញអនុក្រឹត្យ លេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន

- បានឃើញអនុក្រឹត្យលេខ ០២ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- យោងតាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ :** ត្រូវបានតាំងស៊ប់មន្ត្រីរាជការស៊ីវិលរបស់ក្រសួង ស្ថាប័ន ទៅក្នុងក្របខ័ណ្ឌមន្ត្រីក្រមការ ដូចមានរាយនាមខាងក្រោម ៖

| ល.រ | នាម និងគោត្តនាម | ភេទ | ថ្ងៃ-ខែ-ឆ្នាំកំណើត | ឋានន្តរស័ក្តិ និងថ្នាក់ |
|---|---|---|---|---|
| **ទីស្តីការគណៈរដ្ឋមន្ត្រី** | | | | |
| តាំងស៊ប់គិតចាប់ពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១០ តទៅ | | | | |
| ១ | **ឡុង ទ្រា** | ប | ១៥-០៨-១៩៨២ | មន្ត្រីក្រមការ ថ្នាក់លេខ ១៤ |
| ២ | **គីម សេងអាន** | ប | ១៥-០៣-១៩៨៣ | មន្ត្រីក្រមការ ថ្នាក់លេខ ១៤ |
| ៣ | **ម៉ី សុខា** | ប | ២៩-០៦-១៩៨៤ | មន្ត្រីក្រមការ ថ្នាក់លេខ ១៤ |
| ៤ | **អៀម ជីវ័ន្ត** | ប | ១៣-០៦-១៩៨៥ | មន្ត្រីក្រមការ ថ្នាក់លេខ ១៤ |
| ៥ | **លឹម ឈុនលាង** | ប | ១៥-០២-១៩៨៥ | មន្ត្រីក្រមការ ថ្នាក់លេខ ១៤ |
| ៦ | **ទុយ ម៉េងឈាង** | ប | ១៣-០៦-១៩៨៨ | មន្ត្រីក្រមការ ថ្នាក់លេខ ១៤ |
| **រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ** | | | | |
| តាំងស៊ប់គិតចាប់ពីថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០១០ តទៅ | | | | |
| ១ | **ច្រាំ ផល្លា** | ប | ១៥-១២-១៩៨០ | មន្ត្រីក្រមការ ថ្នាក់លេខ ១៤ |
| ២ | **តែត ដូនី** | ស | ០៤-០១-១៩៨០ | មន្ត្រីក្រមការ ថ្នាក់លេខ ១៤ |
| ៣ | **ប្រាក់ ធារត** | ប | ០៨-០១-១៩៧៧ | មន្ត្រីក្រមការ ថ្នាក់លេខ ១៤ |

**មាត្រា ២ :** ត្រូវបានតាំងស៊ប់មន្ត្រីរាជការស៊ីវិលរបស់ក្រសួង ស្ថាប័ន ទៅក្នុងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម ដូចមានរាយនាមខាងក្រោម ៖

| ល.រ | នាម និងគោត្តនាម | ភេទ | ថ្ងៃ-ខែ-ឆ្នាំកំណើត | ឋានន្តរស័ក្តិ និងថ្នាក់ |
|---|---|---|---|---|
| **ក្រសួងសាធារណការ និងដឹកជញ្ជូន** | | | | |
| តាំងស៊ប់គិតចាប់ពីថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០១០ តទៅ | | | | |
| ១ | **ខ្វាន់ ដានី** | ស | ០៩-០៩-១៩៨៣ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ២ | **ឈុំ ដា** | ប | ០៦-០៥-១៩៨៣ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ៣ | **គីម ចរិយា** | ស | ១២-០៩-១៩៨៤ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ៤ | **ចាប សៀន** | ប | ០៩-០៦-១៩៨៣ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |

| | | | | |
|---|---|---|---|---|
| ៥ | ប៊ិច សុខវណ្ណារ៉ា | ប | ១៨-១១-១៩៨២ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| **ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | | | | |
| តាំងស៊ប់គិតចាប់ពីថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១០ តទៅ | | | | |
| ១ | អ៊ុច ហឿន | ប | ០៩-១១-១៩៨៥ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ២ | ពៅ លីណា | ស | ៣០-១០-១៩៨៤ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ៣ | ថា ស៊ីថន | ស | ០៩-០៣-១៩៨៥ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ៤ | សុខ លីដា | ប | ០៥-០៣-១៩៨៣ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ៥ | ចន ផល្លីន | ប | ០៣-០៧-១៩៨៤ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ៦ | ជុំ មល្លិកា | ស | ១៥-០១-១៩៨៤ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ៧ | ស្រេង ស្តើង | ស | ០៧-០៨-១៩៨៦ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ៨ | អុង រដ្ឋា | ស | ១៥-១១-១៩៨៣ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ៩ | ឡេង ច័ន្ទសុភា | ប | ១៧-០១-១៩៨៧ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ១០ | ជួន ប៊ុនធឿត | ប | ១០-០៤-១៩៨០ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ១១ | លឹម សារុត | ប | ០២-០២-១៩៨៣ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ១២ | ធឿន រ៉ាទី | ស | ១០-០១-១៩៨៦ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ១៣ | តី ចាន់ធា | ប | ២៨-០៩-១៩៨២ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ១៤ | ទី សុខៅ | ស | ០៥-០៨-១៩៨៧ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ១៥ | សួន សុវណ្ណលក្ខិណា | ស | ១៦-០៧-១៩៨៤ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ១៦ | នុត តូរិន | ប | ១៤-០៣-១៩៨៤ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ១៧ | ស៊ីវ ចាន់ធីកា | ស | ០៣-០៨-១៩៨៤ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ១៨ | អ៊ុំ តុលា | ប | ១៣-១១-១៩៨៦ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ១៩ | ណាត ប៊ុនធឿន | ប | ១០-០៦-១៩៨៤ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ២០ | គង់ ឧត្តម | ប | ១៥-១២-១៩៨៦ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ២១ | ឆាវ សារិន | ប | ១៧-១២-១៩៨៤ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ២២ | ឈុំង ចាន់ធូ | ប | ០៣-០៣-១៩៨៤ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ២៣ | ផាន់ មន្ថា | ប | ០២-០៥-១៩៨២ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ២៤ | សេង សៅ | ប | ០៩-១០-១៩៨៣ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ២៥ | ពៅ សុម៉ាលី | ប | ០៣-០៣-១៩៨៥ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ២៦ | ស្រី សុភ័ក្រ | ស | ២០-១១-១៩៨៦ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ២៧ | ប្រាជ្ញ ឆ្លាត | ប | ០៥-១០-១៩៨៥ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ២៨ | អែម សំអ៊ឹន | ប | ០៥-០៥-១៩៨៥ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ២៩ | ឈឹម គីម | ប | ០៣-០៩-១៩៨៣ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |

| | | | | |
|---|---|---|---|---|
| ៣០ | លេក ស៊ីណារ៉ាន | ប | ០៤-០៦-១៩៨៥ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ៣១ | ចោទ គឹមសាន | ប | ០៤-១១-១៩៨៦ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ៣២ | អាន ពុទ្ធីដា | ស | ២៣-០៧-១៩៨៧ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ៣៣ | ចាន់ រដ្ឋា | ប | ២៤-១០-១៩៨៦ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ៣៤ | សោត័ណ្ណ ម៉ូនីតា | ស | ០៣-០១-១៩៨៩ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ៣៥ | ញ៉ី ស៊ិម | ប | ០៤-០២-១៩៨៦ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ៣៦ | ឈាន សុឃីម | ស | ២៧-០៧-១៩៨៧ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ៣៧ | លី ឌី | ប | ០៦-០៤-១៩៨៥ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ៣៨ | លាច សុវណ្ណលក្ខិណា | ស | ៣១-១២-១៩៨៥ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ៣៩ | ដុន ដាច | ប | ២០-០៧-១៩៨៥ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ៤០ | គោត សុជាតា | ស | ៣០-០៤-១៩៨៣ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ៤១ | សុខ ស្មើ | ស | ២៣-០៦-១៩៨៦ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ៤២ | ញ៉ឹក លឿត | ប | ១៥-០៦-១៩៨៣ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ៤៣ | ជា ម៉ូនីន | ប | ១៨-០៩-១៩៨៥ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ៤៤ | ហ៊ុន សារ៉េតថន | ប | ០១-០១-១៩៨៥ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ៤៥ | ប៉ូច ចាន់ថុនី | ស | ០៧-០៦-១៩៨៤ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ៤៦ | អេង តាំងស៊ី | ស | ១០-១០-១៩៨៤ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ៤៧ | ហ៊ិន សើន | ប | ១០-០៦-១៩៨៤ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ៤៨ | អ៊ិ ស៊ីវអ៊ី | ស | ០១-០២-១៩៨៧ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ៤៩ | ឆេព គុលសុតា | ប | ០៧-០៥-១៩៨៥ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ និងមាត្រា ២ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ធ ឆ្នាំ ២០១០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល*

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៤២៦ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ

### សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនជាកិច្ចបច្ឆាមរណៈ ចំពោះសពលោក **តាត ម៉ិនណា** ប្រធានការិយាល័យបច្ចេកទេសនៃផ្នែកស៊ើបអង្កេតនៃអង្គភាពប្រឆាំងអំពើពុករលួយ ដែលបានទទួលមរណភាព ដោយគ្រោះថ្នាក់ចរាចរ ក្នុងពេលបំពេញភារកិច្ចកន្លងមក ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ... ខែ ... ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួលៈ**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១២៦៨ . អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

**សម្រេច**

**មាត្រា ១.-**

ត្រូវបានបំពាក់ មេដាយមុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការនិងសប្បុរសជន ចំនួន០៧រូប ដែលមានស្នាដៃល្អ ក្នុងការជួយកសាងអភិវឌ្ឍន៍មូលដ្ឋានភូមិ ឃុំ មួយចំនួនក្នុងស្រុកទ្រាំង ខេត្តតាកែវ ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ:**

១-លោក លី សុត សប្បុរសជននៅភ្នំពេញ

២-លោកស្រី ជា ម៉ុនលី អនុប្រធាននាយកដ្ឋានថវិកា ហិរញ្ញវត្ថុ ក្រសួងសុខាភិបាល

**ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា:**

១-លោក យុន ស៊ូគ្រីន ប្រធានមជ្ឈមណ្ឌលលើកកំពស់សុខភាព ក្រសួងសុខាភិបាល

២-លោក ឡាក់ ឡេង អនុប្រធានមជ្ឈមណ្ឌលលើកកំពស់សុខភាព ក្រសួងសុខាភិបាល

៣-លោក ស៊ុន ឆាយ មន្ត្រីគយនៅកំពង់ផែក្រុងព្រះសីហនុ

៤-លោក យុត សារិនឌី មន្ត្រីគយនៅខេត្តព្រៃវែង

៥-លោក នុង ប៊ុនធឿន មន្ត្រីគយនៅខេត្តកំពង់ចាម

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស និងអភិបាលនៃគណៈអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ [illegible] បានលទ្ធផលល្អ ។

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ [illegible] ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៧០៩ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយថ្នាក់ស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០៣រូប រស់នៅសហរដ្ឋអាមេរិក ដែលបានផ្តល់ថវិកា ក្នុងការជួយកសាងអគារសិក្សា០១ខ្នង មាន០៣បន្ទប់ និងបង្គន់អនាម័យ ០១ខ្នង ព្រមទាំងបំពាក់គ្រឿងសង្ហារិមគ្រប់គ្រាន់ ជូនដល់សាលាបឋមសិក្សាភូមិថ្មី ស្ថិតនៅក្នុងឃុំដូង ស្រុករមាសហែក ខេត្តស្វាយរៀង ដូចមានរាយនាមខាងក្រោម ៖

| | |
|---|---|
| ១-លោក ប៊ុត ប៊ុនហាន និងអ្នកស្រី នួន ផល | ថវិកាចំនួន ៧.០០០ ដុល្លារ |
| ២-លោក ឌិត្យ សួនី និងអ្នកស្រី ម៉ាយ សាទន់ | ថវិកាចំនួន ៧.០០០ ដុល្លារ |
| ៣-លោក ម៉ៅ ចំរើន និងអ្នកស្រី ឌិត្យ សូរិយា | ថវិកាចំនួន ៧.០០០ ដុល្លារ |

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តស្វាយរៀង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១២៧០.អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

### សម្រេច

**ប្រការ ១.-**

ត្រូវបានបំពាក់ មេដាយការងារ តាមលំដាប់ថ្នាក់ ចំនួន ១០៧ គ្រឿង ជូនមន្ត្រីរាជការនៃក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ចំនួន ១០៧រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ នាពេលកន្លងមក ដូចមានរាយនាមខាងក្រោម៖

**ក-មេដាយមាសការងារ**

| | | | |
|---|---|---|---|
| ១- | លោក | អ៊ឹ សុផាន់ណារ៉ា | ប្រធាននាយកដ្ឋានសុខុមាលភាពកុមារ |
| ២- | លោក | ជួរ រតនះ | នាយកបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល |
| ៣- | លោក | ទ្រាំ ឆន | នាយករងបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល |
| ៤- | លោក | អ៊ឹក បូរ៉ា | អនុប្រធានការិយាល័យ នៃនាយករងបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល |
| ៥- | លោក | អ៊ំ សុខហេង | អនុប្រធាននាយកដ្ឋានផែនការ ស្ថិតិ និងសរុប |
| ៦- | លោក | ម៉ៅ សំបូរ | អនុប្រធាននាយកដ្ឋានសោធននិវត្តន៍ |
| ៧- | លោកស្រី | ជ័យ ណារ៉ាត្រី | អនុប្រធាននាយកដ្ឋានសោធននិវត្តន៍ |
| ៨- | លោកស្រី | អៀន ផល្លី | អនុប្រធាននាយកដ្ឋានសោធននិវត្តន៍ |
| ៩- | លោក | ប៊ូ សុខាឌី | អនុប្រធាននាយកដ្ឋានយុវនីតិសម្បទា |
| ១០- | លោកស្រី | អ៊ុំ វណ្ណាឫទ្ធី | អនុប្រធាននាយកដ្ឋានសុខុមាលភាពសង្គម |

| | | | |
|---|---|---|---|
| ១១- | លោកស្រី | យួន ឆវីវណ្ណា | ប្រធានការិយាល័យហិរញ្ញវត្ថុ នៃនាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ |
| ១២- | លោកស្រី | ចាន់ សុជាវី | ប្រធានការិយាល័យសម្ភារៈ និងផ្គត់ផ្គង់ នៃនាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ |
| ១៣- | លោក | លុក ម៉ុនថា | ប្រធានការិយាល័យយុវនីតិសម្បទា និងទណ្ឌិត នៃនាយកដ្ឋានយុវនីតិសម្បទា |
| ១៤- | លោកស្រី | ម៉េង គួមរី | ប្រធានការិយាល័យពិធីការ នៃនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ |
| ១៥- | លោកស្រី | កែវ ម៉ាលី | ប្រធានការិយាល័យសេវាការពារជនផ្ទុកមេរោគអេដស៍ និងជម្ងឺអេដស៍ នៃនាយកដ្ឋានសុខុមាលភាពសង្គម |
| ១៦- | លោកស្រី | ស្រ៊ាក់ ថាវឥតរី | ប្រធានផ្នែករដ្ឋបាលសិទ្ធិជនពិការ នៃនាយកដ្ឋានស្តារលទ្ធភាពពលកម្ម |
| ១៧- | លោកស្រី | នេត សុជាតា | អនុប្រធានការិយាល័យហិរញ្ញវត្ថុ នៃនាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ |
| ១៨- | លោក | សុខ លីពាមី | អនុប្រធានការិយាល័យហិរញ្ញវត្ថុ នៃនាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ |
| ១៩- | លោកស្រី | ជា សីដាលី | អនុប្រធានការិយាល័យសម្ភារៈ និងផ្គត់ផ្គង់ នៃនាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ |
| ២០- | លោកស្រី | ម៉ែន ម៉ាលីរត្ន | អនុប្រធានការិយាល័យសម្ភារៈ និងផ្គត់ផ្គង់ នៃនាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ |
| ២១- | លោកស្រី | លុយ សុគន្ធា | អនុប្រធានការិយាល័យគ្រប់គ្រង នៃនាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ |
| ២២- | លោកស្រី | ហុង សេងី | អនុប្រធានការិយាល័យគ្រប់គ្រង នៃនាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ |
| ២៣- | លោក | គង់ ឆុន | អនុប្រធានមណ្ឌលយុវនីតិសម្បទាចោមចៅ នៃនាយកដ្ឋានយុវនីតិសម្បទា |
| ២៤- | លោក | ម៉ុក វណ្ណៈ | អនុប្រធានផ្នែកសម្របសម្រួលផ្សព្វផ្សាយរដ្ឋបាលសិទ្ធិជនពិការ នៃនាយកដ្ឋាន ស្តារលទ្ធភាពពលកម្ម |
| ២៥- | លោក | ហៀង សុផាន់ណា | មន្ត្រីនាយកដ្ឋានស្តារលទ្ធភាពពលកម្ម |
| ២៦- | លោក | ឡុង ធីរៈ | មន្ត្រីនាយកដ្ឋានស្តារលទ្ធភាពពលកម្ម |
| ២៧- | លោក | គង់ សារិទ្ធ | មន្ត្រីអគ្គាធិការដ្ឋាន |
| ២៨- | លោក | ពូក សីហា | អនុប្រធាននាយដ្ឋានសោធនអតីតយុទ្ធជន |
| ២៩- | លោកស្រី | និន ភត្តិដ្ឋា | អនុប្រធាននាយដ្ឋានសោធនអតីតយុទ្ធជន |
| ៣០- | លោក | ហុង ស្រីសម្បត្តិ | ប្រធានការិយាល័យ |
| ៣១- | លោក | ឌុន ផលពិសិដ្ឋ | អនុប្រធាននាយកដ្ឋានសុខុមាលភាពកុមារ |

ខ-មេដាយប្រាក់ការងារ:

| | | | |
|---|---|---|---|
| ១- | លោកស្រី | ស៊ិន សារឿន | ប្រធាននាយកដ្ឋានសុខុមាលភាពសង្គម |
| ២- | លោកស្រី | ស៊ាន ប៉ូលីន | អនុប្រធាននាយកដ្ឋានផែនការ ស្ថិតិ និងសរុប |
| ៣- | លោក | នូច សុវណ្ណមុត | អនុប្រធាននាយកដ្ឋានសុខុមាលភាពកុមារ |
| ៤- | លោក | សោម តារៈ | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍អតីតយុទ្ធជន |
| ៥- | លោក | អៀម សារ៉ាត | អនុប្រធាននាយកដ្ឋានសុខុមាលភាពសង្គម |
| ៦- | លោកស្រី | អ៊ុំ សោភ័ណ | ប្រធានការិយាល័យបៀវត្ស នៃនាយកដ្ឋានរដ្ឋបាល និងបុគ្គលិក |
| ៧- | លោកស្រី | ចាន់ តារិទ្ធ | ប្រធានការិយាល័យអភិវឌ្ឍន៍ធនធានមនុស្ស នៃនាយកដ្ឋានរដ្ឋបាល និងបុគ្គលិក |

| | | | |
|---|---|---|---|
| ៨- | លោកស្រី | សៀម សុគន្ធវតី | ប្រធានការិយាល័យសហប្រតិបត្តិការ នៃនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ |
| ៩- | លោកស្រី | យឹម សុបំណាច | ប្រធានការិយាល័យអាស៊ាន នៃនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ |
| ១០- | លោក | ខឹម សំអាត | ប្រធានការិយាល័យអន្តរជាតិ នៃនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ |
| ១១- | លោកស្រី | ឡៃ សុខន | ប្រធានការិយាល័យសេវាទប់ស្កាត់ និងការពារជនអនាថា នៃនាយកដ្ឋានសុខុមាលភាពសង្គម |
| ១២- | លោកស្រី | កែប សុវ៉ានី | អនុប្រធានការិយាល័យ នៃនាយកដ្ឋានសោធនអតីតយុទ្ធជន |
| ១៣- | លោក | គីម តេច | ប្រធានការិយាល័យគ្រប់គ្រងទិន្នន័យ នៃនាយកដ្ឋានអភិវឌ្ឍន៍អតីតយុទ្ធជន |
| ១៤- | លោកស្រី | ហេង ចំន្ទបូលីន | អនុប្រធានការិយាល័យអន្តរជាតិ នៃនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ |
| ១៥- | លោកស្រី | ចាន់ មុជរ៉ាន់ណា | អនុប្រធានការិយាល័យបុគ្គលិក នៃនាយកដ្ឋានរដ្ឋបាល និងបុគ្គលិក |
| ១៦- | លោកស្រី | ហេង្ស រ៉ា | មន្ត្រីនាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ |
| ១៧- | លោកស្រី | ជួន សារ៉ាន់ | មន្ត្រីនាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ |
| ១៨- | លោកស្រី | យឹម ដល្លា | អនុប្រធានការិយាល័យ នៃនាយកដ្ឋានស្តារលទ្ធភាពពលកម្ម |
| ១៩- | លោក | សុខ ផុន | មន្ត្រីនាយកដ្ឋានស្តារលទ្ធភាពពលកម្ម |

**គ-មេដាយសិរីវឌ្ឍនការរ៉ារៈ**

| | | | |
|---|---|---|---|
| ១- | លោកស្រី | ប៊ូ សោភ័ណ | ប្រធានផ្នែករដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ |
| ២- | លោក | នឹង ដារ៉ា | អនុប្រធាននាយកដ្ឋានផែនការ ស្ថិតិ និងសរុប |
| ៣- | លោក | សោម សំអឿន | អនុប្រធាននាយកដ្ឋានសុខុមាលភាពសង្គម |
| ៤- | លោក | ពេជ្រ កុសល | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍អតីតយុទ្ធជន |
| ៥- | លោក | អ៊ុំ ប៊ុនរិទ្ធ | ប្រធានការិយាល័យលេខាធិការដ្ឋានរបស់អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស នៃនាយកដ្ឋានសុខុមាលភាពកុមារ |
| ៦- | លោកស្រី | គីម ចំន្ទសុលីណា | ប្រធានការិយាល័យជីវភាព និងឥណទាន នៃនាយកដ្ឋានអភិវឌ្ឍន៍អតីតយុទ្ធជន |
| ៧- | លោក | លី សុខចុង | ប្រធានការិយាល័យអភិវឌ្ឍន៍ នៃនាយកដ្ឋានអភិវឌ្ឍន៍អតីតយុទ្ធជន |
| ៨- | លោកស្រី | ថៅ ពៅ | អនុប្រធានការិយាល័យថែទាំកុមារ នៃនាយកដ្ឋានសុខុមាលភាពកុមារ |
| ៩- | លោកស្រី | អៀម សុគន្ធារី | អនុប្រធានការិយាល័យបៀវត្ស នៃនាយកដ្ឋានរដ្ឋបាល និងបុគ្គលិក |
| ១០- | លោក | យឹម កំសាន្ត | អនុប្រធានការិយាល័យស្ថិតិ នៃនាយកដ្ឋានផែនការ ស្ថិតិ និងសរុប |
| ១១- | លោក | ម៉ី យឿន | អនុប្រធានការិយាល័យសេវាការពារជនផ្ទុកមេរោគអេដស៍ និងជម្ងឺអេដស៍ នៃនាយកដ្ឋានសុខុមាលភាពសង្គម |
| ១២- | លោក | ពេជ សេរី | អនុប្រធានការិយាល័យសង្គ្រោះសង្គម នៃនាយកដ្ឋានសុខុមាលភាពសង្គម |
| ១៣- | លោកស្រី | សុខ ធី | អនុប្រធានការិយាល័យប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្ម នៃនាយកដ្ឋានសុខុមាលភាពសង្គម |
| ១៤- | លោកស្រី | ជា សុម៉ាលី | អនុប្រធានការិយាល័យប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្ម នៃនាយកដ្ឋានសុខុមាលភាពសង្គម |
| ១៥- | លោក | លី ឡេងមុន្នីកែវ | អនុប្រធានការិយាល័យសង្គ្រោះសង្គម នៃនាយកដ្ឋានសុខុមាលភាពសង្គម |

| | | | |
|---|---|---|---|
| ១៦- | លោក | ទូច សុន្ធស៊ីណា | អនុប្រធានការិយាល័យសេវាទប់ស្កាត់ និងការពារជនអនាថានៃ នាយកដ្ឋានសុខុមាលភាពសង្គម |
| ១៧- | លោកស្រី | គីម ណារីន | អនុប្រធានការិយាល័យប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្ម នៃនាយកដ្ឋានសុខុមាលភាពសង្គម |
| ១៨- | លោកស្រី | ម៉ម ដាណែត | អនុប្រធានការិយាល័យសហប្រតិបត្តិការ នៃនាយកដ្ឋានសហប្រតិបត្តិកាតអន្តរជាតិ |
| ១៩- | លោក | កែត ប៊ុនសុន | អនុប្រធានការិយាល័យសហប្រតិបត្តិការ នៃនាយកដ្ឋានអភិវឌ្ឍន៍អតីតយុទ្ធជន |
| ២០- | លោក | ឈន អក្ខរា | អនុប្រធានការិយាល័យគ្រប់គ្រងទិន្នន័យ នៃនាយកដ្ឋានអភិវឌ្ឍន៍អតីតយុទ្ធជន |
| ២១- | លោក | សោម និស្ស័យ | នាយករងបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល |
| ២២- | លោក | មាស ទូ | នាយករងបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល |
| ២៣- | លោក | ធីម បូរាណ | នាយករងបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល |
| ២៤- | លោកស្រី | អ៊ុន ចរិយា | មន្ត្រីនាយកដ្ឋានសុខុមាលភាពសង្គម |
| ២៥- | លោក | ឡូ សុភារិទ្ធ | មន្ត្រីនាយកដ្ឋានផែនការ ស្ថិតិ និងសរុប |
| ២៦- | លោកស្រី | ខៀវ ចាន់នី | មន្ត្រីអគ្គាធិការដ្ឋាន |
| ២៧- | លោកស្រី | ណែម សូនីន | មន្ត្រីអគ្គាធិការដ្ឋាន |
| ២៨- | លោកស្រី | រស់ សេរីរតនៈ | មន្ត្រីអគ្គាធិការដ្ឋាន |
| ២៩- | លោកស្រី | សួន សុផល | មន្ត្រីនាយកដ្ឋានរដ្ឋបាល និងបុគ្គលិក |
| ៣០- | លោក | ប៉ែន ជីវ័ន្ត | មន្ត្រីនាយកដ្ឋានរដ្ឋបាល និងបុគ្គលិក |
| ៣១- | លោក | ឈួន ដារ៉ា | មន្ត្រីនាយកដ្ឋានរដ្ឋបាល និងបុគ្គលិក |
| ៣២- | លោក | សន សុគារី | មន្ត្រីនាយកដ្ឋានរដ្ឋបាល និងបុគ្គលិក |
| ៣៣- | លោក | ខុម ផលលឿន | មន្ត្រីនាយកដ្ឋានរដ្ឋបាល និងបុគ្គលិក |
| ៣៤- | លោក | អៀម សុផល | មន្ត្រីនាយកដ្ឋានរដ្ឋបាល និងបុគ្គលិក |
| ៣៥- | លោក | សឿន រ័ត្នា | មន្ត្រីនាយកដ្ឋានរដ្ឋបាល និងបុគ្គលិក |
| ៣៦- | លោក | ទូច ដារ៉ុម | មន្ត្រីនាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ |
| ៣៧- | លោក | អ៊ីុច កេននធី | មន្ត្រីនាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ |
| ៣៨- | លោក | ទ្រាំ ស៊ីុវណ្ណៈ | មន្ត្រីនាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ |
| ៣៩- | លោកស្រី | ជា ភានីន | មន្ត្រីនាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ |
| ៤០- | លោកស្រី | ទ្រាំ ស៊ីុថា | មន្ត្រីនាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ |
| ៤១- | លោក | តា មានិត | មន្ត្រីនាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| ៤២- | លោក | សម សតា | មន្ត្រីនាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| ៤៣- | លោកស្រី | លី គីមលៀង | មន្ត្រីនាយកដ្ឋានសោធននិវត្តន៍ |
| ៤៤- | លោកស្រី | ប្រុក ម៉ែកវិជ្ជា | មន្ត្រីនាយកដ្ឋានសោធននិវត្តន៍ |
| ៤៥- | លោក | ប៊ុត ចាន់ធី | មន្ត្រីនាយកដ្ឋានសហប្រតិបត្តិកាតអន្តរជាតិ |
| ៤៦- | លោក | អ៊ូ គង់ផល | មន្ត្រីនាយកដ្ឋានសហប្រតិបត្តិកាតអន្តរជាតិ |

| | | | |
|---|---|---|---|
| ៤៧- | លោកស្រី | ម៉ៅ សោភា | មន្ត្រីនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ |
| ៤៨- | លោក | ណុប ឫទ្ធា | មន្ត្រីអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ |
| ៤៩- | លោកស្រី | គិត សារណា | មន្ត្រីអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ |
| ៥០- | លោកស្រី | សម សោភា | មន្ត្រីអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ |
| ៥១- | លោក | ជួ សត្យា | មន្ត្រីអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ |
| ៥២- | លោក | សុក សុផាន់ណា | មន្ត្រីនាយកដ្ឋានសោធនអតីតយុទ្ធជន |
| ៥៣- | លោក | ផាន់ គីម | មន្ត្រីនាយកដ្ឋានសោធនអតីតយុទ្ធជន |
| ៥៤- | លោកស្រី | អ៊ុំ វណ្ណាសិទ្ធី | មន្ត្រីនាយកដ្ឋានសោធនអតីតយុទ្ធជន |
| ៥៥- | លោក | ឌី រតនា | មន្ត្រីនាយកដ្ឋានសោធនអតីតយុទ្ធជន |
| ៥៦- | លោក | សេង ម៉ិនឡេង | មន្ត្រីនាយកដ្ឋានអភិវឌ្ឍន៍អតីតយុទ្ធជន |
| ៥៧- | លោក | ទ៉ាន់ សុទិសាល | មន្ត្រីនាយកដ្ឋានអភិវឌ្ឍន៍អតីតយុទ្ធជន |

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៧៥ . សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមឆ្មាំឆ្នេរសមុទ្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងទេសចរណ៍
- យោងតាមសំណូមពរចាំបាច់

## សម្រេច

**ប្រការ ១ :** បង្កើតឱ្យមានក្រុមឆ្មាំឆ្នេរសមុទ្រកម្ពុជា ដើម្បីត្រួតពិនិត្យ ថែរក្សា ការពារសុវត្ថិភាព និងសង្គ្រោះដល់ភ្ញៀវ ដែលមកកំសាន្តនៅតាមរមណីយដ្ឋានឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នេរសាធារណៈ និងឆ្នេរឯកជន)។

**ប្រការ ២** : ក្រុមឆ្មាំឆ្នេរសមុទ្រកម្ពុជាមានតួនាទី និងភារកិច្ច ដូចខាងក្រោម÷

- ត្រួតពិនិត្យ និងឃ្លាំមើលសកម្មភាពកំសាន្តរបស់ភ្ញៀវនៅតាមរមណីយដ្ឋានឆ្នេរសមុទ្រ
- ផ្តល់ការសង្គ្រោះជាបន្ទាន់ដល់ភ្ញៀវដែលជួបគ្រោះថ្នាក់នៅតាមរមណីយដ្ឋានឆ្នេរសមុទ្រ
- ផ្តល់ការសង្គ្រោះបឋមដល់ជនដែលទទួលរងគ្រោះថ្នាក់
- ទទួលការផ្តល់ព័ត៌មានអំពីគ្រោះថ្នាក់ដែលកើតមាននៅតាមរមណីយដ្ឋានឆ្នេរសមុទ្រ
- ពន្យល់ និងផ្សព្វផ្សាយអំពីគ្រោះថ្នាក់ដែលអាចកើតមានឡើងជាយថាហេតុ
- សហការជិតស្និទ្ធជាមួយស្ថាប័ន ភ្នាក់ងារមានសមត្ថកិច្ច ឬភ្នាក់ងារសង្គ្រោះបន្ទាន់ (រថយន្តសង្គ្រោះបន្ទាន់ មន្ទីរពេទ្យ ស្ថានីយឧតុនិយម ភ្នាក់ងារសន្តិសុខ ។ល។)
- ចូលរួមថែរក្សាស្លាកសញ្ញា ទង់សញ្ញា ពោងកំណត់ជម្រៅទឹក
- ថែរក្សាសម្ភារៈសង្គ្រោះ ដូចមានចែងក្នុងប្រការ៨ ឱ្យបានត្រឹមត្រូវ និងគង់វង្ស
- ផ្តល់របាយការណ៍ប្រចាំថ្ងៃដល់អ្នកគ្រប់គ្រង។

**ប្រការ ៣** : លក្ខខណ្ឌដើម្បីក្លាយជាឆ្មាំឆ្នេរសមុទ្រ មានដូចខាងក្រោម÷

- ត្រូវមានអាយុចាប់ពី ១៨ឆ្នាំឡើង
- មានកាយសម្បទារឹងមាំ
- មានជំនាញច្បាស់លាស់ខាងហែលទឹក និងសង្គ្រោះជនរងគ្រោះពីទឹក
- មានចំណេះដឹងខាងសង្គ្រោះបឋម
- មានចំណេះដឹងភាសាអង់គ្លេសដែលអាចប្រើប្រាស់បាន
- ត្រូវឆ្លងកាត់វគ្គបណ្តុះបណ្តាល ដោយទទួលស្គាល់ពីក្រសួងទេសចរណ៍។

**ប្រការ ៤** : ឆ្មាំឆ្នេរសមុទ្រត្រូវបានជ្រើសរើសក្នុងក្របខណ្ឌកិច្ចសន្យាការងារ ឬសេវាឯកជនដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាជ្ញាធរខេត្តតំបន់ឆ្នេរសមុទ្រ។

ឆ្មាំឆ្នេរសមុទ្រត្រូវបំពេញភារកិច្ចរបស់ខ្លួនក្នុងតំបន់ដែលបានកំណត់ដោយអាជ្ញាធរខេត្តតំបន់ឆ្នេរសមុទ្រ។

**ប្រការ ៥** : ក្រុមឆ្មាំឆ្នេរសមុទ្រកម្ពុជាមាននិមិត្តសញ្ញា ដូចដែលបានកំណត់ក្នុងឧបសម្ព័ន្ធទី១។

**ប្រការ ៦** : ក្រុមឆ្មាំឆ្នេរសមុទ្រកម្ពុជាត្រូវសហការជាមួយស្ថានីយឧតុនិយម រដ្ឋបាលជលផល និងស្ថាប័នពាក់ព័ន្ធ ក្នុងការកំណត់ និងលើកទង់សញ្ញាដែលត្រូវប្រើប្រាស់នៅតាមឆ្នេរសមុទ្រ។ ទង់សញ្ញាត្រូវកំណត់ក្នុងឧបសម្ព័ន្ធទី២។

**ប្រការ ៧** : ឯកសណ្ឋានរបស់ឆ្មាំឆ្នេរសមុទ្រត្រូវបានរចនាឡើង ដើម្បីងាយស្រួលក្នុងការចំណាំ និងបង្ហាញភាពខុសប្លែកពីមជ្ឈដ្ឋានសាធារណៈ។

ឯកសណ្ឋានរបស់ឆ្មាំឆ្នេរសមុទ្រកម្ពុជាមានលក្ខណៈ ដូចខាងក្រោម÷

- អាវយឺតពណ៌ទឹកក្រូច ដែលមានរំលេចអក្សរខ្មែរ "**ឆ្មាំឆ្នេរសមុទ្រ**" នៅពីខាងមុខ និងអក្សរអង់គ្លេស "Beach Lifeguard" នៅពីខាងក្រោយ
- ខោខ្លីត្រឹមជង្គង់ពណ៌ទឹកក្រូច

គម្រូលំអិតនៃឯកសណ្ឋានរបស់ឆ្មាំឆ្នេរសមុទ្រត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៣។

**ប្រការ ៨ :** ឆ្មាំឆ្នេរសមុទ្របំពាក់ដោយសម្ភារៈចាំបាច់មួយចំនួនសម្រាប់បំពេញភារងារ ដូចខាងក្រោម÷

- តួបឆ្មាំឆ្នេរសមុទ្រ (ទម្រង់តួបឆ្មាំឆ្នេរសមុទ្រ ដូចដែលបានកំណត់ក្នុងឧបសម្ព័ន្ធទី៤)
- កញ្ចែសម្រាប់បញ្ជា និងព្រមាន
- កែវយឹត
- ឧឃោសនៈស័ព្ទ
- ពោងសង្គ្រោះ
- វិទ្យុសម្រាប់ទាក់ទង
- ប្រអប់សម្ភារៈថ្នាំពេទ្យ និងសម្ភារៈសម្រាប់សង្គ្រោះបឋម
- មធ្យោបាយបម្លាស់ទីសម្រាប់សង្គ្រោះ
- ឧបករណ៍ផ្សេងៗ។

**ប្រការ ៩ :** គ្មានបុគ្គលណាម្នាក់អាចប្រើប្រាស់តួប ឯកសណ្ឋាន និងឧបករណ៍របស់ឆ្មាំឆ្នេរសមុទ្រ ផ្ទុយពីគោលបំណង និងកម្មវត្ថុនៃសេចក្តីសម្រេចនេះឡើយ។

នៅគ្រប់តួបឆ្មាំឆ្នេរសមុទ្រ ត្រូវមានវត្តមានរបស់ឆ្មាំឆ្នេរសមុទ្រយ៉ាងហោចណាស់ម្នាក់នៅប្រចាំការជានិច្ច។

ឆ្មាំឆ្នេរសមុទ្រត្រូវពាក់ឯកសណ្ឋានជាប្រចាំ ក្នុងពេលបំពេញភារកិច្ច។

**ប្រការ១០:** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១១:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០១០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល:***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ១១*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ* ✓

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៧៦. សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការចម្រុះរៀបចំព្រះរាជពិធីបុណ្យចម្រើនព្រះជន្មវស្សាថ្វាយសម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី សម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ ក្នុងគម្រប់ ៦៦ យាងចូល ៦៧ ព្រះវស្សា នៅថ្ងៃទី ២២-២៣ ខែមករា ឆ្នាំ២០១១ នៅវត្តស្វាយពពែ, រាជធានីភ្នំពេញ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## ស ម្រេ ច

**ប្រការ ១ :** បង្កើតគណៈកម្មការចម្រុះរៀបចំព្រះរាជពិធីបុណ្យចម្រើនព្រះជន្មវស្សាថ្វាយសម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី **បួរ គ្រី** សម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ ក្នុងគម្រប់ ៦៦ យាងចូល ៦៧ ព្រះវស្សា ដែលមានសមាសភាព ដូចខាងក្រោម :

| | | |
|---|---|---|
| ១- ឯកឧត្តម | **មិន ឃិន** | ប្រធាន |
| ២- ឯកឧត្តម | **អ៊ុក រ៉ាប៊ុន** | អនុប្រធាន |
| ៣- ឯកឧត្តមបណ្ឌិត | **ម៉ែន ស៊ីម៉ន** | អនុប្រធាន |
| ៤- ឯកឧត្តម | **កែប ជុតិមា** | អនុប្រធាន |

| | | |
|---|---|---|
| ៥- ព្រះពុទ្ធាចារ្យ | ទូច សុខទេវាហារ | សមាជិក |
| ៦- ព្រះមហារាជធម្ម | ខន្ធ អាននេត | សមាជិក |
| ៧- ឯកឧត្តម | ហ៊ីង ម៊ុនហៀង | សមាជិក |
| ៨- ឯកឧត្តម | ហ៊ុន ស៊ីថា | សមាជិក |
| ៩- ឯកឧត្តម | យូ ស៊ុនឡុង | សមាជិក |
| ១០- ឯកឧត្តម | យឹម សារិទ្ធ | សមាជិក |
| ១១- ឯកឧត្តមនាយឧត្តមសេនីយ៍ | នេត សាវឿន | សមាជិក |
| ១២- ឯកឧត្តមនាយឧត្តមសេនីយ៍ | សៅ សុខា | សមាជិក |
| ១៣- ឯកឧត្តម | ជា សុខុម | សមាជិក |
| ១៤- ឯកឧត្តម | ប៊ូន លឹមហេង | សមាជិក |
| ១៥- ឯកឧត្តម | គីម គុណវឌ្ឍន៍ | សមាជិក |
| ១៦- ឯកឧត្តម | ញៀម ទារី | សមាជិក |

**ប្រការ ២ :** គណៈកម្មការចម្រុះរៀបចំព្រះរាជពិធីបុណ្យចម្រើនព្រះជន្មវស្សានេះ មានមុខងារ និងភារកិច្ច ដូចតទៅ :

- សហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និង គណៈសង្ឃនាយក នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីរៀបចំព្រះរាជពិធីបុណ្យចម្រើនព្រះជន្មវស្សា តាមប្រពៃណីព្រះពុទ្ធសាសនាឱ្យប្រព្រឹត្តទៅបានល្អប្រសើរ
- ពិនិត្យ និងលើកសំណើដោះស្រាយរាល់បញ្ហានានា ទាក់ទិននឹងការរៀបចំព្រះរាជពិធីបុណ្យចម្រើនព្រះជន្មវស្សា
- រៀបចំកិច្ចការពារសន្តិសុខ សណ្តាប់ធ្នាប់ក្នុងរៀបចំព្រះរាជពិធីបុណ្យចម្រើនព្រះជន្មវស្សាឱ្យបានល្អប្រសើរ
- ធ្វើលិខិតអញ្ជើញ រៀបចំទទួលបដិសណ្ឋារកិច្ចថ្នាក់ដឹកនាំ និងភ្ញៀវ ដែលអញ្ជើញចូលរួម
- លើកគម្រោង និងចាត់ចែងគ្រប់គ្រងចំណូល-ចំណាយ អំពាវនាវសប្បុរសជន/សិស្សគុណ ស្នើសុំវិភាគទានជាថវិកា និងសម្ភារៈ បម្រើឱ្យព្រះរាជពិធីបុណ្យប្រព្រឹត្តទៅបានរលូន និងល្អប្រសើរ
- បំពេញភារកិច្ចជាក់ស្តែងផ្សេងទៀត តាមការចាំបាច់ សម្រាប់បម្រើឱ្យព្រះរាជពិធីបុណ្យ ។

**ប្រការ ៣ :** គណៈកម្មការចម្រុះនេះ អាចបង្កើតអនុគណៈកម្មការ និងក្រុមការងារជំនាញបន្ថែមជាជំនួយការតាមការចាំបាច់ ដើម្បីធានាឱ្យការរៀបចំព្រះរាជពិធីបុណ្យចម្រើនព្រះជន្មវស្សា ឱ្យប្រព្រឹត្តទៅបានតាមប្រពៃណីព្រះពុទ្ធសាសនា។

**ប្រការ ៤ :** សមាសភាពគណៈកម្មការចម្រុះរៀបចំព្រះរាជពិធីបុណ្យចម្រើនព្រះជន្មវស្សា ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានមានសិទ្ធិពេញលេញក្នុងការដឹកនាំការងាររបស់គណៈកម្មការចម្រុះរៀបចំព្រះរាជពិធីបុណ្យចម្រើនព្រះជន្មវស្សា តាមការប្រគល់សិទ្ធិរបស់ប្រធាន។

**ប្រការ ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u> :**

- សម្តេចព្រះអគ្គមហាសង្ឃរាជ ទាំងពីរគណៈ
- គណៈសង្ឃនាយក
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងការពារជាតិ
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងធម្មការ និងសាសនា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ
- សាលារាជធានីភ្នំពេញ
- ដូចប្រការ ៥
